

**មេធាវីរដ្ឋអាជ្ញាតំបន់មីដ្ឋលសេក្ស**
Gerry Leone

អំពើបំពារបំពានផ្នែកផ្លូវភេទគឺជារបួសគួរឲ្យតក់ស្លុតមួយក្នុងចំណោមរបួសទាំងឡាយដែលក្មេងម្នាក់អាចទទួល។ ភាគច្រើន ក្មេងៗ មិនប្រាប់អ្នកណាម្នាក់អំពីអ្វីដែលកើតឡើងដល់ពួកគេទេ។ ចំពោះក្មេងដែលប្រាប់ វិបត្តិរបស់ពួកគេតែងតែធ្ងន់ធ្ងរឡើងដោយសារការភ័យខ្លាច និងភាពច្របូកច្របល់រាល់ពេលដែលពួកគេត្រូវគេសុំឲ្យនិយាយប្រាប់អំពីអំពើបំពាននោះទៅបុគ្គលណាម្នាក់ថ្មីទៀត។

ពីអតីត ក្មេងៗដែលបានប្រាប់ពីពីការចោទប្រកាន់នៃអំពើបំពានខាងផ្លូវភេទ—ខ្លះអាយុត្រឹមបួន ឬប្រាំឆ្នាំ—ត្រូវគេសួរម្តងហើយម្តងទៀតជាច្រើនដង សម្ភាសដាច់ៗពីគ្នាក្នុងកំឡុងពេលពីរ-បីសប្តាហ៍ដោយជំនាញការផ្សេងៗ ដែលពាក់ព័ន្ធក្នុងការស៊ើបអង្កេតនេះ។ ដើម្បីឆ្លើយតបទៅនឹងភាពតានតឹងដែលក្មេងៗទាំងនេះប្រឈមមុខ អង្គភាពការពារកុមារពីការបំពានធ្វើបាបមីដ្ឋលសេក្សបានបង្កើតវិធានការណ៍ពហុវិន័យលំចិត្តថ្មីមដែលទទួលស្គាល់នូវការកាត់បន្ថយភាពតានតឹងចំពោះក្មេងៗ ដែលមានទុក្ខលំបាករួចទៅហើយ នៅខណៈដែលរក្សានូវខ្នាតគំរូខ្ពស់ត្រឹមត្រូវតាមនីតិក្រមវេជ្ជវិទ្យា។

តាមរយៈប្រព័ន្ធស៊ើបអង្កេតផ្នែកបំពានខាងផ្លូវភេទ(SAIN) ភាពប្រឹងប្រែងសហការគ្នាជាមួយក្រសួងកូនក្មេង និងគ្រួសារ ប៉ូលីសក្រុងនិងការិយាល័យរបស់យើងៗ អាចប្រមូលផ្តុំគ្នានូវជំនាញការនានាដែលពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតនៃការចោទប្រកាន់ពីការបំពានផ្នែកផ្លូវភេទទៅលើកូនក្មេងដោយឲ្យមានតែការថតសម្ភាសន៍តែមួយប៉ុណ្ណោះដែលធ្វើឡើងដោយអ្នកជំនាញដែលមានការហ្វឹកហាត់ពិសេសលើការសម្ភាសន៍ក្មេង។ ក្រោយមកទៀត ការសម្ភាសន៍ក្មេងនោះអាចត្រូវគេប្រើប្រាស់សំរាប់ជាហេតុផលនៃការស៊ើបអង្កេត ហើយនិងចាប់ខ្លួន។ ជារឿយៗ ការសម្ភាសន៍នេះគឺត្រូវធ្វើឡើងតែម្តងគត់ក្នុងកំឡុងពេលស៊ើបអង្កេត ដែលក្មេងត្រូវតែនិយាយរឿងប្រាប់ទៅមនុស្សចំឡែកពីភាពពិស្តារនៃការបំពានទៅលើរូបគេ។

សៀវភៅស្តើងនេះត្រូវបានគេបង្កើតឡើងដើម្បីផ្តល់ជូនលោក-អ្នកនូវបទសង្ខេបនៃដំណើរការ SAIN ខណៈដែលលោក-អ្នកឈានចូលជាកាលៈទេសៈពិបាកសំរាប់ក្មេង និងគ្រួសារ។ លើសពីនេះទៀត លោក-អ្នកត្រូវគេស្វាគមន៍ជានិច្ចឲ្យទាក់ទងអ្នកគាំទ្រសាក្សីជនរងគ្រោះដែលត្រូវគេចាត់តាំងឲ្យកាន់សំណុំរឿងរបស់លោក-អ្នក បើមានសំណួរនិងសេចក្តីងឿងឆ្ងល់ដែលលោក-អ្នកមាន។

## ប្រព័ន្ធធ្វើការស៊ើបអង្កេតពីការរំលោភបំពានផ្នែកផ្លូវភេទ

ដើម្បីធានានូវសុវត្ថិភាព និងការការពារកុមារ ច្បាប់តម្រូវថា ក្រសួងកុមារ និងគ្រួសារ(DCF)
ធ្វើការស៊ើបអង្កេតពីរបាយការណ៍ទាំងឡាយណាពីការ សង្ស័យថាមានការបំពានធ្វើបាបចំពោះកុមារដោយអ្នកមើលបីបាច់ថែរក្សា។
ប្រព័ន្ធធ្វើការស៊ើបអង្កេតពីការរំលោភបំពានផ្នែកផ្លូវភេទ(SAIN) គឺជាកិច្ចប្រតិ បត្តិការណ៍រួមគ្នារវាងការិយាល័យមេធាវីរដ្ឋអាជ្ញាមីដ្ឋលសេក្ស
និង DCF ក្នុងការសម្របសម្រួលកិច្ចបំរើសំរាប់លោក-អ្នក និងគ្រួសាររបស់លោក-អ្នក ខណៈដែលការចោទប្រកាន់របស់កូនលោក-
អ្នកពីការរំលោភបំពានខាងផ្លូវភេទស្ថិតក្រោមការស៊ើបអង្កេត។ គោលបំណងចម្បងនៃក្រុមការងាររបស់ SAIN
គឺដើម្បីកាត់បន្ថយនូវចំនួនពេលដែលកូនរបស់លោក-អ្នកនឹងត្រូវគេសម្ភាសដោយជំនាញការផ្សេងៗ គ្នា។ ក្រុមការ-
ងារក៏សម្របសម្រួលកិច្ចបំរើដល់កូន របស់លោក-អ្នក និងសមាជិកគ្រួសាររបស់លោក-អ្នកដែលមិនបានធ្វើអ្វីខុសឲ្យបានឆាប់រហ័សជាទីបំផុត។
វិធានការណ៍ដូចគ្នានៃក្រុមនេះដែរនឹងត្រូវគេ ប្រើប្រាស់ដើម្បីស៊ើបអង្កេតការចោទប្រកាន់ទាំងឡាយណាទាក់ទងទៅនឹងការធ្វើបាបលើរាងកាយ។

# ការសម្ភាសន៍របស់ SAIN

## សំណួរនានាដែលត្រូវគេសួរជាញឹកញាប់

### តើមានអ្វីកើតឡើងនៅពេលធ្វើការសម្ភាសន៍?

កូនរបស់លោក-អ្នកនឹងត្រូវគេសម្ភាសនៅក្នុងបន្ទប់មួយដែលមានមេត្តាធម៌ចំពោះកុមារ។ មានតែសមាជិកម្នាក់គត់ពីក្រុមការងារនោះ ជាអ្នកជំនាញខាង សម្ភាសន៍ក្មេង
នឹងសួរនាំកូនរបស់លោក-អ្នក។ សមាជិកដទៃទៀតទាំងប៉ុន្មាននឹងសង្កេតមើលកិច្ចសម្ភាសន៍ពីបន្ទប់ជាប់គ្នាតាមរយៈកញ្ចក់ដែលមើលឃើញពី មួយចំហៀង។
អ្នកធ្វើបទសម្ភាសន៍នឹងជួបជាមួយលោក-អ្នក និងកូនរបស់លោក-អ្នកមុនពេលការធ្វើសម្ភាសន៍។ លោក-អ្នកនឹងត្រូវគេសុំឲ្យផ្តល់ការ អនុញ្ញាតដល់កូនរបស់លោក-អ្នក
ដើម្បីឲ្យគេនិយាយជាមួយអ្នកសម្ភាសអំពីអ្វីដែលបានកើតឡើង។ បន្ទាប់មក លោក-អ្នកនឹងត្រូវគេសុំឲ្យរង់ចាំនៅខណៈ ដែលកូនរបស់លោក-អ្នកត្រូវគេសម្ភាស។

### តើវាមានប្រយោជន៍អ្វីក្នុងការឲ្យកូនរបស់ខ្ញុំត្រូវក្រុមការងារសម្ភាស?

DCF គឺជាក្រសួងមួយមាននាទីក្នុងការទទួលរបាយការណ៍ទាំងអស់ពីការសង្ស័យ ថាមានក្មេងត្រូវគេបំពានធ្វើបាប និងមិនយកចិត្តទុកដាក់។ DCF ត្រូវគេ តម្រូវឲ្យបញ្ជូ
នសំណុំរឿងធ្ងន់ធ្ងរខ្លះទៅការិយាល័យមេធាវីរដ្ឋអាជ្ញា និងទៅប៉ូលីស ដើម្បីឲ្យគេអាចធ្វើការស៊ើបអង្កេតទៅបាន។ បើសិនជាជនប្រព្រឹត្តិត្រូវគេ
សង្ស័យនោះគឺជាអ្នកបីបាច់ថែរក្សាក្មេង DCF ក៏ត្រូវគេតម្រូវឲ្យធ្វើការស៊ើបអង្កេតចំពោះរឿងនោះដែរ។ ក្នុងករណីយ៉ាងនេះ ក្រុមការងាររបស់ SAIN នឹង ជួបប្រជុំគ្នា
ដើម្បីឲ្យក្រសួងដែលពាក់ព័ន្ធទាំងប៉ុន្មានអាចធ្វើការស៊ើបអង្កេតរឿងនោះឲ្យបានព្រមគ្នា និងធ្វើការសម្របសម្រួលឲ្យមានការសម្ភាសន៍ជាមួយកូន របស់លោក-អ្នកតែមួយដង។
នៅពេលដែលក្រុមការងាររបស់ SAIN មិនត្រូវបានគេណាត់ធ្វើទេ អ្នកជំនាញការទាំងនោះប្រហែលជាត្រូវការសម្ភាស កូនរបស់លោក-អ្នកម្តងម្នាក់ដាច់ដោយឡែកពីគ្នា។
ដោយកោះហៅប្រជុំរបស់ក្រុមការងារ សេវាកម្មសំរាប់គ្រួសាររបស់លោក-អ្នកនឹងត្រូវគេសម្រប សម្រួលឲ្យបានប្រសើរឡើង ហើយលោក-
អ្នកនឹងមានឱកាសដើម្បីជួបជាមួយអ្នកជំនាញទាំងឡាយពីក្រសួងដែលពាក់ព័ន្ធនានាទាក់ទងទៅនឹងសំណុំរឿង របស់កូនលោក-អ្នក ហើយនិងសួរសំណួរណាដែលលោក-
អ្នកអាចមាន។

### តើនេះនឹងជាចុងបញ្ចប់ប៉ុណ្ណោះដែលកូនរបស់ខ្ញុំត្រូវតែនិយាយអំពីការរំលោភធ្វើបាប?

វាជាការសំខាន់ក្នុងការយល់ថា ការចូលរួមក្នុងកម្មវិធីនេះមិនមែនបានសេចក្តីថា កូនរបស់លោក-អ្នកនឹងមិនត្រូវនិយាយពីការរំលោភធ្វើបាបនេះម្តងទៀត។ មេធាវីរងរដ្ឋអាជ្ញា
និងអ្នកជួយគាំទ្រសាក្សីជនរងគ្រោះនឹងពិភាក្សាជាមួយលោក-អ្នកលើការសំរេចចិត្តរបស់មេធាវីរដ្ឋអាជ្ញា ថាតើគួរតែផ្តន្ទាទោសឬអត់ ហើយនិងពិភាក្សាពី-
ការពាក់ព័ន្ធរបស់កូនលោក-អ្នកនៅក្នុងដំណើរការក្នុងតុលាការ។ លើសពីនេះទៅទៀត កុមារអាចនៅតែបន្តការនិយាយពីអ្វីដែលកើត ឡើងចំពោះពួកគេនៅក្នុងពេលព្យាបាល
ដែលជាមធ្យោបាយមួយនៃការដោះស្រាយតាមរយៈអារម្មណ៍ឬផ្លូវចិត្តរបស់ពួកគេ។

### តើខ្ញុំគួរតែត្រៀមខ្លួនកូនរបស់ខ្ញុំសំរាប់ការសម្ភាសន៍ដែរឬយ៉ាងម៉េច?

ក្មេងៗ ហាក់ដូចជាមានការងាយស្រួលបំផុតនៅពេលដែលពួកគេត្រូវ បានគេប្រាប់នូវអ្វីនឹងកើតឡើង។ វាជាការសំខាន់ណាស់ដើម្បីពន្យល់ ទៅកូនរបស់លោក-អ្នក
ថាពួកគេនឹងជួបជាមួយអ្នកជំនាញការដើម្បី និយាយពីអ្វីដែលបានកើតឡើង។ លោក-អ្នកអាចឲ្យកូនរបស់លោក-អ្នកដឹងពីមនុស្សដែលត្រូវសួរសំណួរ ថាគេគឺជាមនុស្ស-
ម្នាក់ដែលមាន នាទីខាងនិយាយជាមួយក្មេង ហើយធ្វើយ៉ាងម៉េចឲ្យក្មេងនោះមានសុវត្ថិ ភាព។ លោក-អ្នកមិនគួរបង្ហាប់ឲ្យកូនលោក-អ្នកនិយាយឡើយ ប៉ុន្តែ
គ្រាន់តែប្រាប់នាងឲ្យនិយាយពីការពិត។ ក្មេងៗ ខ្លះប្រហែលជាត្រូវការ ការធានាអះអាងសារជាថ្មី ថានាងនឹងមិនមានបញ្ហាអ្វីទេ ហើយពួក នាងមិនមែនទៅជួបគេនោះដោយ-
សារតែនាងបានធ្វើអ្វីខុសនោះឡើយ។ អ្នកដែលសម្ភាសនឹងចំណាយពេលជាមួយកូនរបស់លោក-អ្នកមុនពេល ធ្វើការសម្ភាសន៍
ដើម្បីពន្យល់ពីដំណើរការនិងឆ្លើយសំណួររបស់នាង។

### តើខ្ញុំអាចនៅជាមួយកូនរបស់ខ្ញុំបានទេ ក្នុងពេលសម្ភាសន៍?

វាជាការសំខាន់សំរាប់អ្នកសម្ភាសន៍និយាយជាមួយកូនរបស់លោក-អ្នក តែម្នាក់ឯង។ ជាធម្មតា វាមានការលំបាកសំរាប់ក្មេងក្នុងការនិយាយពី ការរំលោភបំពានផ្នែកផ្លូវភេទ
ហើយវត្តមានរបស់មាតាបិតាអាចរំខាន ឬក៏ជាឧបសគ្គដល់ក្មេងក្នុងពេលសម្ភាសន៍។ ក្មេងៗ ក៏អាចបែរទៅឪ ពុកម្តាយដើម្បីឲ្យឆ្លើយសំណួរឲ្យពួកគេ។ វាជាការប្រសើរបំផុត
បើក្មេង អាចផ្តល់ព័ត៌មានដោយម្ចាស់ការខ្លួនឯង។

### តើខ្ញុំអាចមើលការសម្ភាសន៍ជាមួយក្រុមការងារបានដែរ ឬអត់?

សមាជិកក្រុមការងារត្រូវការសង្កេតមើល ធ្វើការវាយតម្លៃ និងកត់ត្រា ដោយប្រយ័ត្នប្រយែង ដែលជាផ្នែកមួយនៃការស៊ើបអង្កេតបទឧក្រិដ្ឋ។ លោក-
អ្នកប្រហែលជាអាចត្រូវគេហៅទៅធ្វើជាសាក្សីក្នុងការផ្តន្ទាទោស ណាមួយក្រោយមកទៀត ដូច្នេះមាតាបិតាមិនត្រូវនៅជាមួយក្រុមការ ងារបានទេនៅពេលសម្ភាសន៍។

### តើខ្ញុំអាចនាំមិត្តភក្តិឬសមាជិកគ្រួសារម្នាក់ទៅជាមួយខ្ញុំនៅថ្ងៃសម្ភាសនោះ បានដែរ ឬអត់?

យើងខ្ញុំជំរុញឲ្យលោក-អ្នកនាំសមាជិកគ្រួសារឬក៏មិត្តភក្តិម្នាក់ទៅជាមួយ ដើម្បីឲ្យបាននៅជាមួយលោក-អ្នកខណៈដែលកូនលោក-អ្នកត្រូវគេ កំពុងតែសម្ភាស និងឲ្យនៅជាមួ-
យកូននៅពេលដែលលោក-អ្នកជួបជា មួយក្រុមការងារ។

## សមាជិកក្រុមការងាររបស់ SAIN

**មេធាវីរងរដ្ឋអាជ្ញា**

ការិយាល័យមេធាវីរដ្ឋអាជ្ញាមានកាតព្វកិច្ចទទួលខុសត្រូវ និងអំណាចក្នុងការសំរេច ថាតើសំណុំរឿងនោះគួរតែធ្វើការផ្តន្ទាទោសនៅក្នុងស្រុកមីដ្តលសេក្ស៍( Middlesex County )ឬអត់។ មេធាវីរដ្ឋនឹងធ្វើការសំរេច ថាតើវាមានភស្តុតាងគ្រប់គ្រាន់ដើមី្បចាប់ផ្តើមដំណើរការចោទប្រកាន់បែបបទឧក្រិដ្ឋឬអត់ ហើយគិតមើលថា តើគួរតែធ្វើការចាប់ខ្លួនក្នុងបទឧក្រិដ្ឋឬទេ បន្ទាប់ពីធ្វើការពិភាក្សាគ្នាជាមួយក្រុមការងាររបស់ SAIN ពីផលប្រយោជន៍ដ៏ល្អបំផុតរបស់ក្មេង។

**អ្នកជួយគាំទ្រដល់សាក្សីជនរងគ្រោះ**

នេះគឺជាមនុស្សដែលលោក-អ្នកត្រូវជួបច្រើនជាងគេបង្អស់នៅការិយាល័យមេធាវីរដ្ឋអាជ្ញា។ អ្នកជួយគាំទ្រនឹងផ្តល់ជូនលោក-អ្នកនូវព៌តមានពីសិទ្ធិរបស់ជនរងគ្រោះ ប្រាប់ពីការបារម្ភផ្នែកសុវត្ថិភាព ហើយនិងជួយលោក-អ្នកឲ្យទទួលបានការគាំទ្រដែលសមរម្យ និងប្រភពព៌តមានផ្សេងៗ។ បើសិនជាសំណុំរឿងត្រូវទៅក្នុងតុលាការ ពួកគេនឹងពន្យល់ពីដំណើរការក្នុងតុលាការ ផ្តល់ព៌តមានថ្មីៗ និងនាំលោក-អ្នកទៅតុលាការ។

**អ្នកជំនាញខាងសម្ភាសន៍កុមារ/អ្នកសំរបសំរួលក្រុមការងាររបស់ SAIN**

នេះគឺជាអ្នកជំនាញដែលមានការហ្វឹកហាត់ពិសេសក្នុងការសម្ភាសន៍តាមនីតិវេជ្ជសាស្ត្រចំពោះកុមារដែលប្រហែលត្រូវទទួលការបំពានធ្វើបាបឬបានឃើញប្រចក្សនូវបទឧក្រិដ្ឋធ្ងន់ធ្ងរ បន្ទាប់ពីគេសំរេចថា វាជាការសមគួរតាមកំរិតនៃការលូតលាស់របស់ក្មេង សុខភាពផ្លូវចិត្ត និងភាពតានតឹងក្នុងចិត្តរបស់ក្មេងនៅពេលនេះ។ អ្នកសម្ភាសន៍នេះក៏ជាអ្នកដែលសំរបសំរួលជាមួយ DCF ប៉ូលីស និងការិយាល័យមេធាវីរដ្ឋអាជ្ញាមីដ្តលសេក្សផងដែរ ដើមី្បរៀបចំនិងចាត់ចែងឲ្យមានការសម្ភាសន៍ដោយក្រុមការងារ។

**អ្នកស៊ើបអង្កេតរបស់ DCF**

ក្រសួងកុមារ និងគ្រួសារ(DCF) គឺជាក្រសួងរបស់រដ្ឋដែលត្រូវគេប្រគល់នាទីឲ្យទទួលខុសត្រូវក្នុងការពារកុមារពីការរំលោភធ្វើបាប និងមិនយកចិត្តទុកដាក់ដោយអ្នកថែរក្សាពួកគេ ហើយនិងពង្រឹងក្រុមគ្រួសារ។ បុគ្គលិកការងារសង្គមម្នាក់ដែលធ្វើការស៊ើបអង្កេតចូលរួមធ្វើការសម្ភាសន៍នីតិវេជ្ជវិទ្យា ធ្វើការស៊ើបអង្កេតមួយដើមី្បសម្រេចថា តើគួរតែគាំទ្ររបាយការណ៍មាត្រា៥១A ដែរឬអត់ និងធ្វើសេចក្តីសម្រេចថាតើ DCF នឹងបើកសំណុំរឿងមួយជាមួយគ្រួសារដើមី្បឲ្យមានការជួយគាំទ្រ និងសេវាកម្មដែរឬអត់។

**ប៉ូលីស:**

ប៉ូលីសស៊ើបអង្កេតធ្វើការអង្កេតស្រាវជ្រាវករណីចោទប្រកាន់ពីបទឧក្រិដ្ឋ។ មន្ត្រីប៉ូលីសម្នាក់មកពីក្រុង ឬថោនដែលមានករណីចោទប្រកាន់រំលោភធ្វើបាបបានកើតឡើង ឬប៉ូលីសរដ្ឋពីរដ្ឋម៉ាស្សាជូសេត្ស៍នឹងទទួលខុសត្រូវក្នុងការប្រមូលភស្តុតាង ធ្វើការសម្ភាសន៍សាក្សី និងប្រហែលជាសម្ភាសជនសង្ស័យផង នឹងធ្វើការចាប់ខ្លួននៅពេលណាសមរម្យ និងជួយធានាសុវត្ថិភាពរបស់កុមារ និងគ្រួសារ។

## អង្គភាពការពារកុមារពីការបំពានធ្វើបាប

### នៃការិយាល័យការពារគ្រួសារតំបន់មីដ្តលសេក្ស៍

អង្គភាពការពារកុមារពីការបំពានធ្វើបាបគឺជាក្រសួងដែលមានមេត្តាធម៌ដល់កុមារស្ថិតនៅក្នុងការិយាល័យការពារគ្រួសារនៃការិយាល័យមេធាវីរដ្ឋអាជ្ញាមីដ្តលសេក្ស៍ ដែលគេបានបង្កើតឡើងក្នុងឆ្នាំ១៩៨៩ ដើមី្បធានានូវការឆ្លើយតបរបស់ក្រុមពហុវិន័យដែលមានការយល់ចិត្តថ្លើម និងដោះស្រាយករណីកុមារដែលមានការបំពានធ្វើបាប។ អង្គភាពការពារកុមារពីការបំពានធ្វើបាបដោះស្រាយករណីទាំងអស់នៃអំពើរំលោភផ្លូវភេទ និងការធ្វើបាបដ៏ធ្ងន់ធ្ងរលើរាងការរបស់កុមារដែលមានអាយុក្រោម ១៨ឆ្នាំ។ បុគ្គលិកប្រជុំជើងដោយអ្នកជំនាញការដែលប្តូរផ្តាច់ និងយកចិត្តទុកដាក់ តាំងចិត្តធ្វើការជាមួយ និងធ្វើជាតំណាងឲ្យកុមារជនរងគ្រោះ ហើយនិងគ្រួសាររបស់ពួកគេ។ ក្មេងគ្រប់រូបដែលចេញមុខប្រាប់ពីការចោទប្រកាន់នៃការរំលោភធ្វើបាប និងឪពុកម្តាយ ឬអាណាព្យាបាលរបស់នាងត្រូវគេតែងតាំងមនុស្សមួយក្រុមដែលមានមេធាវីរងរដ្ឋអាជ្ញាម្នាក់ អ្នកជំនាញខាងសម្ភាសន៍កុមារម្នាក់ ហើយនិងអ្នកជួយគាំទ្រសាក្សីជនរងគ្រោះ ដើមី្បជួយពួកគេឲ្យឆ្លងកាត់ប្រព័ន្ធតុលាការខាងបទឧក្រិដ្ឋ។

អង្គភាពការពារកុមារពីការបំពានធ្វើបាប ធ្វើការរួមគ្នាជាមួយមន្ទីរជួយការពារកុមារមីដ្តលសេក្ស៍ ប្តេជ្ញាបញ្ចេញសម្លេងឲ្យអ្នកទាំងឡាយណាដែលបើមិនអញ្ចឹងទេនោះនឹងមិនមានសម្លេងនៅក្នុងប្រព័ន្ធតុលាការខាងបទឧក្រិដ្ឋឡើយ ហើយការសហការនោះនឹងកាត់បន្ថយនូវក្តីឈឺចាប់ជាលើកទីពីររបស់កុមារជនរងគ្រោះដោយកាត់ចោលភាពវែងអន្ទាយនៃការដោះស្រាយករណីកុមារដែលរងការរំលោភធ្វើបាប និងត្រូវគេងយកផលប្រយោជន៍។

**ប្រភពនានាបន្ថែមទៀត**

*Middlesex Children's advocacy Center*

***មជ្ឈមណ្ឌលគាំទ្រកុមារមីដ្តលសេក្ស៍***

*www.middlesexcac.com*

*Department of*
*Children and Families*

***ក្រសួងកុមារ និងគ្រួសារ***

*www.mass.gov/dcf*

**ចង្កោមរបស់ SAIN**



**ទៅកាន**

**ការស៊ើបអង្កេតអំពើរំលោភផ្លូវភេទលើកុមារ**

**មគ្គុទេសក៍សំរាប់**

**មាតាបិតា និង អាណាព្យាបាល**

**មេធាវីរដ្ឋអាជ្ញាតំបន់មីដ្តលសេក្ស៍**

Gerry Leone

**អង្គភាពការពារកុមារពីការរំលោភធ្វើបាប**

The Child Abuse Unit
15 Commonwealth Avenue
Woburn, MA 01801
(781) 897-8400

*www.middlesexda.com*

***ដើមី្បរាយការណ៍ពីកុមារដែលរងការរំលោភធ្វើបាប***
***ឬមិនយកចិត្តទុកដាក់ សូមទូរស័ព្ទ***
*Child-At-Risk-Hotline 1-800-792-5200*